Belgium
partner in development

WWF



© Sambo Chheng / WWF-Cambodia

# «វីរនារីដៃឯក» ខ្ញុំពិការដៃម្ខាងពិតមែន ប៉ុន្តែខ្ញុំមិនពិការមនសិការឡើយ ករណីសិក្សារបស់ កញ្ញា យ៉ោ ស្រីឡា បង្ហាញពីភាពអង់អាច ដើម្បីការពារធនធានធម្មជាតិ ដែលជាទីជម្រករបស់សហគមន៍

បើយើងធ្វើដំណើរកាត់តាមព្រៃសហគមន៍អូគ្រៀង ដែលស្ថិតនៅក្នុងដែនជម្រកសត្វព្រៃសំបូរ នោះយើងនឹងឃើញមានផ្លូវដីក្រហម ហើយមានព្រៃរបោះក្រាស់ៗគួរឱ្យទាក់ទាញ។ ព្រៃសហគមន៍នេះនៅឆ្ងាយបន្តិចពីស្នាក់ការរបស់មន្ត្រីឧទ្យានុរក្ស ប៉ុន្តែនៅទីនោះ យើងក៏មានការចូលរួមរបស់សហគមន៍មូលដ្ឋានផងដែរ ដើម្បីការពារព្រៃឈើរបស់ពួកគេទៅនឹងសកម្មភាពការកាប់ឈើខុសច្បាប់ និងការគំរាមកំហែងដល់សត្វព្រៃ។ នៅក្នុងសហគមន៍នោះក៏មាន ស្រីឡា គឺជាសមាជិកល្បាតសហគមន៍ និងជាស្ត្រីមានពិការភាពម្នាក់ ដែលមានការលះបង់ និងពោរពេញដោយការប្តេជ្ញា ដើម្បីការពារធនធានធម្មជាតិនៅក្នុងសហគមន៍។



កាលដែល  ស្រីឡា ចូលរួមនៅក្នុងការងារអភិរក្សនេះ គឺមិនមែនគ្រាន់តែជាការចូលរួមដោយការស្រលាញ់ និងការចូលចិត្តឡើយ ប៉ុន្តែក៏បានបង្ហាញពីភាពអង់អាចក្លាហានផងដែរ។ នៅអាយុត្រឹម ១៣ ឆ្នាំ ស្រីឡា បានបាត់បង់ដៃឆ្វេងម្ខាងក្នុងឧបទ្ទវហេតុដ៏រន្ធត់មួយ ខណៈពេលដែលកំពុងជួយការងាររបស់ម្តាយនៅឯការដ្ឋានឡូតដូ។




**«ខ្ញុំកើតមកមិនមានន័យថា ខ្ញុំមិនអាចធ្វើអ្វីៗបានទេ ហើយគ្រប់យ៉ាង គឺខ្ញុំអាចធ្វើបាន បើទោះបីជាខ្ញុំពិការដៃម្ខាងក៏ដោយ។»**

ស្រីឡា ក៏បានរំលឹកឡើងវិញផងដែរពីអតីតកាល ដោយបង្ខំចិត្តឈប់រៀន ហើយចំណាយពេលជួយការងារចិញ្ចឹមជ្រូក និងលក់គ្រឿងទេសនៅផ្ទះជាមួយម្តាយនៅក្នុងសហគមន៍។

ទោះបីជា ស្រីឡា ពុំមានមានបទពិសោធន៍ ឬចំណេះដឹងអំពីការងារល្បាតព្រៃឈើក៏ពិតមែន ប៉ុន្តែស្រីឡា ក៏មិនដែលនឹកស្មានដែរថា ថ្ងៃណាមួយរូបគេអាចនឹងបំពេញតួនាទីនេះ ហើយអាចចូលរួមជាមួយសហគមន៍ ដើម្បីការពារធនធានដ៏មានតម្លៃបំផុតរបស់សហគមន៍។ រហូតដល់ឆ្នាំ ២០១៨ នៅពេលលោកឪពុកធម៌របស់ ស្រីឡា ដែលជាសមាជិកល្បាត សហគមន៍ក៏បានណែនាំ និងបានលើកទឹកចិត្តឱ្យចូលរួមក្រុមល្បាតជាមួយសហគមន៍។

**« ពុកធម៌របស់ខ្ញុំ ប្រាប់ខ្ញុំថា សហគមន៍ត្រូវការមានស្ត្រីម្នាក់នៅក្នុងក្រុមល្បាត ជាពិសេស ដើម្បីជួយការងារក្នុងស្ថានភាពដែលចាំបាច់ត្រូវមានការងារសម្របសម្រួលដោយមនុស្សស្រី ហើយពេលនោះ ខ្ញុំឆ្លើយភ្លាមដោយពុំស្ទាក់ស្ទើរឡើយ គឺនិយាយថា ខ្ញុំធ្វើទទួលការងារនេះ!»**

ស្រីឡា បាននិយាយថា៖ «ព្រៃឈើ គឺជាផ្នែកមួយដ៏សំខាន់នៃជីវិតរបស់យើង ប្រសិនបើយើងបាត់បង់នោះយើងបាត់បង់អ្វីៗទាំងអស់ទៅតាមនោះដែរ។»

ដែនជម្រកសត្វព្រៃសំបូរ ក៏មិនមានអ្វីខុសពីដែនជម្រកសត្វព្រៃផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ដែលកំពុងទទួលរងសម្ពាធពីសកម្មភាពនៃការកាប់ឈើខុសច្បាប់ ការបរបាញ់សត្វព្រៃ និងការទន្ទ្រានយកដីព្រៃជាដើម។ ក្រុមល្បាតជាញឹកញាប់ គឺក្រុមដែលស្ថិតនៅជួរមុខគេ ដើម្បីការពារនៅ ពេលមានបទល្មើសទកើតឡើង។ ប៉ុន្តែសម្រាប់ ស្រីឡា ទាំងសមត្ថភាព និងធនធាន គឺនៅមានកម្រិតនៅឡើយទេ ពីព្រោះការងារនៅក្នុងក្រុមល្បាតសហគមន៍នេះតែងតែប្រឈមមុខនឹងបញ្ហាជាច្រើន ជាពិសេសសម្រាប់ស្ត្រីដូចជា ស្រីឡា ដែលជាស្ត្រីមានពិការភាពតែម្តង។ នៅពេលដែល ស្រីឡា ក្លាយជា សមាជិកក្រុមល្បាតសហគមន៍ គឺស្រីឡា តែងតែជម្នះនូវរាល់បញ្ហាដែលអ្នកភូមិស្រុកគេចោទប្រកាន់ ឬមាក់ងាយ ហើយមួយវិញទៀតនោះ គឺការសម្របសម្រួលការគិតចំពោះខ្លួនឯងផងដែរ។

ស្រីឡា បាននិយាយថា «ខ្ញុំភ័យខ្លាចនៅថ្ងៃដំបូងនៃការងាររបស់ខ្ញុំ ជាពិសេសនោះខ្ញុំបានគិតថា ចុះបើមាននរណាម្នាក់វាយប្រហារមកលើខ្ញុំ? ប៉ុន្តែក្រោយមក ខ្ញុំបានរកឃើញពីភាពខ្លាំងនៅក្នុងក្រុម ហើយមានជំនឿយ៉ាងម៉ុតមាំថា យើងកំពុងធ្វើរឿងដែលត្រឹមត្រូវ។»





© Sambo Chheng / WWF-Cambodia



© Sambo Chheng / WWF-Cambodia

តាមរយៈការងារជារឿយៗ បានបង្ហាញឱ្យ ស្រីឡា បានដឹង និងរៀនសូត្រជាច្រើនយ៉ាងឆាប់រហ័ស។ ជាក់ស្តែង ស្រីឡា អាចជិះម៉ូតូដោយប្រើតែដៃម្ខាងយ៉ាងប៉ិនប្រសប់ចូលទៅក្នុងព្រៃជ្រៅៗ ឆ្លងកាត់អូរ ផ្លូវភក់ និងផ្លូវរអិល។ ស្រីឡា មានតួនាទីជាអ្នកកត់ត្រាសកម្មភាពបទល្មើស ប្រើប្រាស់ GPS ថតរូបជាភស្តុតាង និងរៀបចំរបាយការណ៍ ដែលការងារនេះដូចទៅនឹងការងាររបស់មន្ត្រីឧទ្យានុរក្សដែរ។

ស្រីឡាបានបន្តថា៖ «យើងដើរល្បាតពីព្រលឹមរហូតដល់ពេលរសៀល ហើយពេលខ្លះត្រូវនៅក្នុងព្រៃរហូតដល់យប់ និងស្នាក់នៅទីនោះ ប្រសិនបើចាំបាច់។ ជាពិសេសនោះ ប្រសិនបើមានការរាយការណ៍ភ្លាមៗណាមួយអំពីបទល្មើស នោះក្រុមយើងនឹងទៅភ្លាមដោយមិនដែលគិតថាថ្ងៃឬយប់ ឬធ្វើតាមផែនការឡើយ ព្រោះយើងគិតថាវាចាំបាច់ និងជាការប្តេជ្ញាចិត្ត។»

វត្តមានរបស់ ស្រីឡា គឺបានបង្ហាញឱ្យឃើញពីស្រ្តីដ៏រឹងមាំម្នាក់។ ស្រីឡា បានពន្យល់ថា៖ « នៅពេលដែលយើងជួបស្រ្តី និងបុរសនៅក្នុងបទល្មើស គឺខ្ញុំអាចចូលសម្របសម្រួល ដើម្បីបញ្ចៀសជម្លោះដែលអាចកើតឡើង  ពីព្រោះការទំនាក់ទំនងរបស់មនុស្សស្រីពេលខ្លះអាចប្រសើរជាងបុរស។»

ក្រៅតែពីការងារល្បាតសហគមន៍ ស្រីឡា ក៏បានរួមចំណែកជួយធ្វើការងារផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងដល់សហគមន៍ ដោយពន្យល់ពីភាពខុសគ្នារវាងការប្រមូលអនុផលព្រៃឈើប្រកបដោយនិរន្តរភាព និងការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ឬក៏ការបរបាញ់សត្វព្រៃ។



© Sambo Chheng / WWF-Cambodia

**«ខ្ញុំបានពន្យល់ថា បើយើងគ្រាន់តែទាញធនធានពីព្រៃឈើដែលបានអនុញ្ញាត ដូចជាអនុផលព្រៃឈើ គឺមិនចោទជាបញ្ហាឡើយ ប៉ុន្តែការកាប់ឈើ និងបរបាញ់សត្វព្រៃ គឺជាសកម្មភាពខុសច្បាប់»។**

ទោះបីជាពលេនេះ ស្រីឡា ហាក់បីដូចជាទទួលបានជំនាញ និងបទពិសោធន៍កាន់តែរីកចម្រើន ប៉ុន្តែ ស្រីឡា ក៏បាននឹងកំពុងប្រឈមទៅនឹងបញ្ហាមួយចំនួនផងដែរនៅក្នុងសហគមន៍។ សមាជិកសហគមន៍មួយចំនួនបានរិះគន់ ស្រីឡា ចំពោះការរាយការណ៍អំពីសកម្មភាពបទល្មើសដោយចោទប្រកាន់ ស្រីឡា មិនស្មោះត្រង់នឹងអ្នកជិតខាង។

**ស្រីបានពន្យល់ថា៖ «សហគមន៍ខ្លះបាននិយាយដើមខ្ញុំ ហើយពេលនោះខ្ញុំពិតជាទទួលយកមិនបានទេ ប៉ុន្តែខ្ញុំបានក្រើនរំលឹកខ្លួនឯងថា ខ្ញុំមិនធ្វើគ្រប់យ៉ាង គឺដើម្បីឱ្យគេសរសើរឡើយ ពីព្រោះខ្ញុំធ្វើនេះក៏ព្រោះតែខ្ញុំខ្វល់អំពីផលប៉ះពាល់នៅក្នុងសហគមន៍អំពីការបាត់បង់ធនធានធម្មជាតិតែប៉ុណ្ណោះ»។**

ស្រីឡា ជឿថាសកម្មភាពរបស់នាងចំពោះសហគមន៍ គឺបានបង្ហាញអំពីការពិតអស់ហើយ។ «ថ្ងៃណាមួយសគមន៍ពួកគាត់នឹងយល់ ពីព្រោះបើយើងមិនការពារព្រៃនេះទេ នោះវានឹងគ្មានអ្វីនៅសេសសល់សម្រាប់មនុស្សជំនាន់ក្រោយឡើយ»។

ករណីសិក្សារបស់ ស្រីឡា គឺជាសាច់រឿងដ៏មានសារៈសំខាន់ដែលបានបង្ហាញអំពីរបៀបដែលសមាជិកសហគមន៍ ជាពិសេសជាស្ត្រី និងជនមានពិការភាពអាចដើរតួនាទីជាអ្នកការពារព្រៃឈើ និងសត្វព្រៃ ទោះបីជាស្រីឡា មិនមានមុខងារជាមន្ត្រីឧទ្យានុរក្សក៏ដោយ។ ជាក់ស្តែងបើទោះបីជា ស្រីឡា នៅមានការខ្វះខាតខ្លះពិតមែន ប៉ុន្តែ ស្រីឡា ក៏បានបង្ហាញពីសេចក្តីក្លាហាន ភាពធន់ និងការតាំងចិត្តខ្ពស់មិនងាករេចំពោះការងារអភិរក្ស។

ក្រុមសហគមន៍ល្បាតរបស់ ស្រីឡា តែងតែសរសើរ ស្រីឡា ចំពោះវិន័យ និងការធ្វើការងារជាក្រុម។

## «សហគមន៍បានហៅខ្ញុំថា នារីដែឯក ឬមន្ត្រីឧទ្យានុរក្សដៃម្ខាង»

ស្រីឡា ញញឹមតិចៗ ហើយពោលពាក្យថា៖ «ខ្ញុំនឹងមិនចាកចេញពីក្រុមល្បាតសហគមន៍ឡើយ គ្រប់យ៉ាងដែលសហគមន៍ផ្តល់ឱ្យខ្ញុំពេលនេះ គឺខ្ញុំទទួលបាននូវភាពកក់ក្តៅ ហើយត្រូវបានសមាជិកក្រុមឱ្យតម្លៃ និងមើលថែយកចិត្តចាត់ទុកដាក់បានយ៉ាងប្រសើរដូចទៅនឹងសមាជិកនៅក្នុងក្រុមដទៃទៀតដែរ ពីព្រោះតែខ្ញុំមិនដែលបោះបង់ការតាំងចិត្តចំពោះការងារអភិរក្សឡើយ។»

ករណីសិក្សារបស់ ស្រីឡា និងភាពជាអ្នកដឹកនាំបានក្រើនរំលឹកដល់មនុស្សគ្រប់រូប គឺម្នាក់ៗមានតួនាទីក្នុងការងារអភិរក្ស។ កាតព្វកិច្ចការពារធនធានធម្មជាតិគឺជាទំនួលខុសត្រូវរបស់មនុស្សគ្រប់រូប ដើម្បីចូលរួម និងការពារឱ្យខានតែបាន។ ស្រីឡា មិនមែនគ្រាន់តែជាសមាជិកល្បាតសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែ ស្រីឡា ក៏បានធ្វើឱ្យយើងបានស្គាល់ថារូបគេ គឺជាអ្នកការពារជាគំរូ និងជានិមិត្តរូបនៃក្តីសង្ឃឹម។ ជាមួយគ្នានេះដែរ ស្រីឡា ក៏បានបង្ហាញថា មនុស្សគេមិនអាចមើលតែពីសំបកក្រៅនោះទេ ប៉ុន្តែយើងត្រូវតែឱ្យតម្លៃទៅលើសេចក្តីក្លាហាន និងការតាំងចិត្ត ដើម្បីសម្រេចនូវរាល់គោលបំណង។



Working to sustain the natural world for the benefit of people and wildlife.

WWF

together possible

panda.org

© 2025
© 1986 Panda symbol WWF - World Wide Fund for Nature (Formerly World Wildlife Fund)
® “WWF” is a WWF Registered Trademark. WWF Avenue du Mont-Bland, 1196 Gland, Switzerland. Tel: +41 22 364 9111. Fax: +41 22 364 0332.

For contact details and further information, please visit our international website at www.panda.org

© Sambo Chheng / WWF-Cambodia